ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងរដ្ឋប្បវេណីលេខ ៧៥

ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១

សាលក្រមលេខៈ ២០ "ញ"/២៣៨

ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១

បានថតចម្លងត្រឹមត្រូវចេញពីច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី

សៀមរាប, ថ្ងៃទី០៩ ខែ[illegible] ឆ្នាំ២០២១

ក្រឡាបញ្ជី

ធី សុណា

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ

ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្ត

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្ត

**ដើមចោទ៖** ក្រុមហ៊ុន [redacted] ([redacted]) មានអាសយដ្ឋានផ្ទះ [redacted] រាជធានីភ្នំពេញ តំណាងដោយលោក [redacted] ស្រេង ជាតិខ្មែរ ជាប្រធានក្រុមហ៊ុន។

ដោយមានលោក [redacted], លោក [redacted] និងកញ្ញា [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

**ចុងចម្លើយ៖** ឈ្មោះ [redacted] ថុង ភេទប្រុស អាយុ ៥៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅ [redacted]។

## អំពីអង្គហេតុ និងចំណុចវិវាទ

ក.ខ្លឹមសារនៃសាលក្រមដែលសហដើមចោទទាមទារឲ្យតុលាការចេញ៖

១/-ទាមទារសុំឲ្យតុលាការបង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ថុង សងប្រាក់ដើមចំនួន ៨៤.៨៣០.០០០៛ (ប៉ែតសិបបួនលាន ប៉ែតសិបបីម៉ឺនរៀល) ឲ្យទៅដើមចោទវិញ។

២/-ទាមទារសំណងជម្ងឺចិត្ត និងសោហ៊ុយផ្នែកច្បាប់ផ្សេងៗចំនួន ២០.០០០.០០០៛ (ម្ភៃលានរៀល) ពីចុងចម្លើយ។

៣/-សុំឲ្យតុលាការចេញសាលក្រមអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើមចំនួន ៨៤.៨៣០.០០០៛ (ប៉ែតសិបបួនលាន ប៉ែតសិបបីម៉ឺនរៀល)។

## ខ-ដំណើររឿងក្តី និងចំណុចវិវាទៈ

ខ.១.ការសង្ខេបអំពីរឿងក្តី

កន្លងមកចុងចម្លើយឈ្មោះ [redacted] ថុង បានទិញស្រូវពូជ និងជីកសិកម្មពីក្រុមហ៊ុន [redacted] និងបានជំពាក់ប្រាក់ក្រុមហ៊ុននេះចំនួន ៨៤.៨៣០.០០០៛ (ប៉ែតសិបបួនលាន ប៉ែតសិបបីម៉ឺនរៀល)។ រហូតដល់ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ ចុងចម្លើយឈ្មោះ [redacted] ថុង បានធ្វើកិច្ចសន្យាសងប្រាក់ជាមួយក្រុមហ៊ុន ប៉ុន្តែចុងចម្លើយឈ្មោះ [redacted] ថុង មិនបានគោរពតាមកិច្ចសន្យាសងប្រាក់មកក្រុមហ៊ុន។ កន្លងមកក្រុមហ៊ុនបានចេញលិខិតអញ្ជើញឈ្មោះ [redacted] ថុង មកធ្វើការដោះស្រាយប្រាក់ជំពាក់ក្រុមហ៊ុន តែឈ្មោះ [redacted] ថុង មិនចូលខ្លួនមកដោះស្រាយឡើយ។

ខ.២.អង្គហេតុដែលគ្មានវិវាទ

-គូភាគីបានទទួលស្គាល់ថាបានបង្កើតកិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០។

ខ.៣.ចំណុចវិវាទ (គ្មាន)

ខ.៤.ការអះអាងរបស់គូភាគីៈ

ខ.៤.១.ការអះអាងរបស់ដើមចោទ

កន្លងមកចុងចម្លើយឈ្មោះ [redacted] ថុង បានទិញស្រូវពូជ និងជីកសិកម្មពីក្រុមហ៊ុនខ្លួន ហើយនៅជំពាក់ប្រាក់ក្រុមហ៊ុនចំនួន ៨៤.៨៣០.០០០៛ (ប៉ែតសិបបួនលាន ប៉ែតសិបបីម៉ឺនរៀល) ទើបនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ ចុងចម្លើយឈ្មោះ [redacted] ថុង បានធ្វើកិច្ចសន្យាសងប្រាក់ជាមួយក្រុមហ៊ុន ប៉ុន្តែចុងចម្លើយឈ្មោះ [redacted] ថុង មិនបានគោរពតាមកិច្ចសន្យាសងប្រាក់មកក្រុមហ៊ុន។ ក្រុមហ៊ុនបានចេញលិខិតអញ្ជើញឈ្មោះ [redacted] ថុង មកធ្វើការដោះស្រាយប្រាក់ជំពាក់ក្រុមហ៊ុន តែឈ្មោះ [redacted] ថុង មិនចូលខ្លួនមកដោះស្រាយឡើយ។

ខ្លួនសូមឲ្យតុលាការចេញសាលក្រមសម្រេច តាមការស្នើសុំរបស់ខ្លួនដូចខាងក្រោមនេះៈ

១/-ទាមទារសុំឲ្យតុលាការបង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ថុង សងប្រាក់ដើមចំនួន ៨៤.៨៣០.០០០៛ (ប៉ែតសិបបួនលាន ប៉ែតសិបបីម៉ឺនរៀល) ឲ្យទៅដើមចោទវិញ។

២/-ទាមទារសំណងជម្ងឺចិត្ត និងសេវាផ្នែកច្បាប់ផ្សេងៗចំនួន ២០.០០០.០០០៛ (ម្ភៃលានរៀល) ពីចុងចម្លើយ។

៣/-សុំឲ្យតុលាការចេញសាលក្រមអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើមចំនួន ៨៤.៨៣០.០០០៛ (ប៉ែតសិបបួនលាន ប៉ែតសិបបីម៉ឺនរៀល)។

មូលហេតុដែលខាងក្រុមហ៊ុនស្នើសុំឲ្យតុលាការចេញសាលក្រមអនុវត្តបណ្តោះអាសន្នលើប្រាក់ដើមនេះ គឺដោយសារខាងចុងចម្លើយបានទទួលស្គាល់ថាពិតជាបានជំពាក់ប្រាក់ខាងក្រុមហ៊ុនដូចចំនួនដែលខាងក្រុមហ៊ុនទាមទារប្រាកដមែន។

ខ.៤.២.ការអះអាងរបស់ចុងចម្លើយ

ឈ្មោះ [redacted] ថុង ជាចុងចម្លើយបានអវត្តមានដោយពុំមានមូលហេតុ ប៉ុន្តែបានទទួលដីកាកោះហៅរបស់តុលាការត្រឹមត្រូវតាមនីតិវិធីរួចហើយ។

## សំអាងហេតុ

ពាក្យបណ្ដឹង ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់ដើមចោទ ជានីតិបុគ្គល (ក្រុមហ៊ុន [redacted]) ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ តុលាការអាចលើកយកមកធ្វើការទាញហេតុផលដោយផ្ទាល់មាត់បានតាមបញ្ញត្តិមាត្រា ៩ និងមាត្រា ២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

១.តាមសេចក្ដីថ្លែងការណ៍របស់គូភាគី និងតាមការពិនិត្យកិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ គូភាគីមានទំនាក់ទំនងគតិយុត្តិនឹងគ្នា ដោយចុងចម្លើយបានទិញស្រូវពូជ និងជីកសិកម្មពីដើមចោទ ជានីតិបុគ្គល (ក្រុមហ៊ុន [redacted]) និងបានជំពាក់ប្រាក់ដើមចោទចំនួន ៨៤.៨៣០.០០០៛ (ប៉ែតសិបបួនលាន ប៉ែតសិបបីម៉ឺនរៀល) ពិតប្រាកដមែន។ ជាការអនុវត្តកិច្ចសន្យាចុងចម្លើយត្រូវមានកាតព្វកិច្ចសងប្រាក់ឲ្យទៅដើមចោទវិញ ប៉ុន្តែចុងចម្លើយមិនបានអនុវត្តតាមកិច្ចសន្យានោះទេ។

យោងតាមបញ្ញត្តិមាត្រា ៥៧៨ និងមាត្រា ៥៧៩ នៃក្រមរដ្ឋប្បវេណី ,តាមសេចក្ដីថ្លែងការណ៍របស់ដើមចោទ និងការតាមពិនិត្យលើកិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ អាចឲ្យតុលាការទទួលស្គាល់អង្គហេតុនៃការជំពាក់ប្រាក់ចំនួន ៨៤.៨៣០.០០០៛ (ប៉ែតសិបបួនលាន ប៉ែតសិបបីម៉ឺនរៀល) ជាប្រាក់ដែលចុងចម្លើយត្រូវសងឲ្យដើមចោទ។

២.ដើមចោទបានទាមទារសំណងជម្ងឺចិត្ត និងសេវាផ្នែកច្បាប់ផ្សេងៗចំនួន ២០.០០០.០០០៛ (ម្ភៃលានរៀល) ពីចុងចម្លើយ ឃើញថាការទាមទារនេះតុលាការនឹងលើកយកមកពិចារណាផ្អែកលើស្ថានភាពសេដ្ឋកិច្ច ទំហំនៃការខូចខាត និងជីវភាពរបស់ចុងចម្លើយ ស្របតាមបញ្ញត្តិមាត្រា ៤០១ នៃក្រមរដ្ឋប្បវេណី។

៣-ដើមចោទប្ដឹងសុំឲ្យតុលាការចេញសាលក្រម មានអានុភាពអនុវត្តជាបណ្ដោះអាសន្នលើប្រាក់ដើមចំនួន ៨៤.៨៣០.០០០៛ (ប៉ែតសិបបួនលាន ប៉ែតសិបបីម៉ឺនរៀល) តុលាការយល់ឃើញថាការទាមទាររបស់ដើមចោទឲ្យតុលាការចេញសាលក្រមប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្នលើចំណុចនេះតុលាការយល់ឃើញថា យោងតាមមាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី សេចក្ដីសម្រេចដែលប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន គឺមានអានុភាពយកទៅអនុវត្តដូចជាសាលក្រម ឬ សាលដីកាស្ថាពរដែរដូចនេះក្នុងការសម្រេចសេចក្ដីដែលភ្ជាប់នឹងការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ននោះ ត្រូវតែគិតពិចារណាឲ្យបានហ្មត់ចត់បំផុត ម្យ៉ាងទៀតក្នុងករណីមានបណ្ដឹងឧបាស្រ័យចំពោះសេចក្ដីសម្រេចនៅក្នុងសាលក្រមទៅ តុលាការជាន់ខ្ពស់នោះអាចនឹងមានការផ្លាស់ប្ដូរនៅត្រង់ចំណុចណាមួយក្នុងសេចក្ដីសម្រេចឲ្យអនុវត្តជាបណ្ដោះអាសន្ន ជាហេតុធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីទាំងសងខាង។ ហេតុដូច្នេះតុលាការគប្បីសម្រេចប្រានចោលនូវការទាមទាររបស់ដើមចោទខាងលើ។

៤.ប្រាក់ប្រដាប់ក្ដី អនុវត្តតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្ដីសម្រេចបញ្ចប់

១-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] **ផុខ** សងប្រាក់ចំនួន ៨៤.៨៣០.០០០៛ (ប៉ែតសិបបួនលាន ប៉ែតសិបបីម៉ឺនរៀល) ឲ្យទៅដើមចោទឈ្មោះ [redacted] **ស្រេខ** ជាតំណាងឲ្យក្រុមហ៊ុន [redacted]។

២-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] **ផុខ** សងប្រាក់ជំងឺចិត្តចំនួន ១០.០០០.០០០៛ (ដប់លានរៀល) ឲ្យទៅដើមចោទឈ្មោះ [redacted] **ស្រេខ** ជាតំណាងឲ្យក្រុមហ៊ុន [redacted] ([redacted]) ការទាមទារលើសពីនេះត្រូវច្រានចោល ។

៣-ច្រានចោលការទាមទាររបស់ដើមចោទត្រង់ចំណុចឲ្យអនុវត្តជាបណ្ដោះអាសន្នលើចំណុចទី១ នៃ សេចក្ដីសម្រេចបញ្ចប់ខាងលើ ជាអាសារបង់។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១។

ទុក្ខសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍នឹងសាលក្រមនេះតាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

សៀមរាប ,ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]